ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងឧស្សាហកម្មភាពយន្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែ[illegible] ស្តីពីការគ្រប់គ្រងនិងត្រួតពិនិត្យសិល្បៈភាពយន្តនិងវីដេអូ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងជានានូវការគ្រប់គ្រងនិងការអភិវឌ្ឍឧស្សាហកម្មភាពយន្ត ដើម្បីរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចសង្គម ព្រមទាំងថែរក្សា ការពារ លើកតម្កើង និង អភិវឌ្ឍវប្បធម៌ជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅៈ

- គ្រប់គ្រងការផលិតស្នាដៃភាពយន្តក្នុងស្រុក
- គ្រប់គ្រងការផលិតស្នាដៃភាពយន្តរបស់បរទេសនៅព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងការនាំចេញ នាំចូលផលិតផលភាពយន្ត
- គ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្មស្នាដៃភាពយន្ត
- គ្រប់គ្រងការផ្សព្វផ្សាយស្នាដៃភាពយន្ត
- គ្រប់គ្រងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈភាពយន្ត
- លើកទឹកចិត្តដល់ការបង្កើតស្នាដៃភាពយន្តថ្មី
- ត្រួតពិនិត្យនិងបង្ក្រាបបទល្មើសឧស្សាហកម្មភាពយន្ត។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តទៅលើគ្រប់សកម្មភាពទាំងអស់នៃឧស្សាហកម្មភាពយន្ត នៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែការផលិត ការចែកចាយ ការផ្សព្វផ្សាយស្នាដៃភាពយន្ត និង ការផ្សព្វផ្សាយជាសាធារណៈ ដោយក្រសួង ស្ថាប័ន ក្នុងគោលដៅមិនធ្វើអាជីវកម្មរកប្រាក់ចំណេញ។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជា ឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

# ជំពូកទី២
# សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ការគ្រប់គ្រងឧស្សាហកម្មភាពយន្តជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

# ជំពូកទី៣
# ការអនុញ្ញាត ការផលិត ការធ្វើអាជីវកម្ម និងការធ្វើសេវាកម្មភាពយន្ត

**មាត្រា៦ .-**

បុគ្គលដែលប្រកបអាជីវកម្មផលិតស្នាដៃភាពយន្ត អាជីវកម្មភាពយន្ត អាជីវកម្មរោងបញ្ចាំងភាពយន្ត សេវាកម្មផ្គត់ផ្គង់សម្ភារៈថតភាពយន្ត សេវាកម្មកាត់តដំឡើងរូបភាព ផ្គុំសំឡេង និងថតចម្លងភាពយន្ត សេវាកម្មបកប្រែបញ្ចូលសំឡេងភាពយន្ត សេវាកម្មស្ទូឌីយោថតភាពយន្ត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈភាពយន្ត ត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

បែបបទនិងនីតិវិធីនៃការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**មាត្រា៧ .-**

មុននឹងផលិតស្នាដៃភាពយន្ត ផលិតករភាពយន្តត្រូវយកអត្ថបទនិពន្ធភាពយន្តជាភាសាខ្មែរដាក់ជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ពិនិត្យនិងយល់ព្រមជាមុន ដើម្បីទទួលបានលិខិតអនុញ្ញាតផលិតស្នាដៃភាពយន្ត លើកលែងតែការផលិតភាពយន្តភាគទូរទស្សន៍ដោយផ្ទាល់របស់ស្ថានីយទូរទស្សន៍សម្រាប់ចាក់ផ្សាយតាមស្ថានីយទូរទស្សន៍។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវពិនិត្យនិងឆ្លើយតបថាយល់ព្រមឬមិនយល់ព្រម ឬតម្រូវឲ្យមានការសម្រួលអត្ថបទនិពន្ធភាពយន្តឡើងវិញក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ។ ករណីក្រសួងមិនបានឆ្លើយតបក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ត្រូវចាត់ទុកថាយល់ព្រម។

**មាត្រា៨ .-**

ត្រូវហាមឃាត់ពល់ការផលិតស្នាដៃភាពយន្តដែលមានខ្លឹមសារៈ

- ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋាន...
- ប៉ះពាល់ដល់ការសម្ងាត់របស់ជាតិនិងសន្តិសុខជាតិ
- ប៉ះពាល់ដល់ស្ថាប័នរបស់រដ្ឋ...

- មួលបង្កាច់ការពិតប្រវត្តិសាស្ត្រជាតិ
- ប៉ះពាល់ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម
- បំផ្លិចបំផ្លាញប្រពៃណីវប្បធម៌ជាតិ វប្បធម៌ជនជាតិ និងសីលធម៌សង្គម
- ញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ជាតិពន្ធុ ក្រុមជាតិ ឬសាសនា។

**មាត្រា៩ ._**

ត្រូវហាមឃាត់រាល់ការផលិត ការចែកចាយ និងការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃភាពយន្តអាសអាភាស។

**មាត្រា១០ ._**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីសម្រួលរាល់ការផលិតស្នាដៃភាពយន្តនៅព្រះរាជាណាចក្រកម្ពុជា។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាចស្នើសុំបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសម្រួលក្នុងការផលិតស្នាដៃភាពយន្តនៅព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការពិនិត្យខ្លឹមសារនិងរូបភាព ការធ្វើចំណាត់ថ្នាក់ និងការផ្តល់ទិដ្ឋាការស្នាដៃភាពយន្ត

**មាត្រា១១ ._**

ស្នាដៃភាពយន្តក្នុងស្រុកឬនាំចូលពីបរទេស មុននឹងយកទៅធ្វើអាជីវកម្មជួល លក់ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ និងស្នាដៃភាពយន្តនាំចេញទៅក្រៅប្រទេស ត្រូវមានការអនុញ្ញាតពីម្ចាស់សិទ្ធិនិងត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការពិនិត្យខ្លឹមសារនិងរូបភាព ការធ្វើចំណាត់ថ្នាក់ និងការផ្តល់ទិដ្ឋាការស្នាដៃភាពយន្តជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

បែបបទ នីតិវិធី និងរយៈពេលនៃការពិនិត្យខ្លឹមសារនិងរូបភាព ការធ្វើចំណាត់ថ្នាក់ និងការផ្តល់ទិដ្ឋាការស្នាដៃភាពយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការពិនិត្យខ្លឹមសារនិងរូបភាព ការធ្វើចំណាត់ថ្នាក់ និងការផ្តល់ទិដ្ឋាការស្នាដៃភាពយន្តលើការផលិតភាពយន្តភាគទូរទស្សន៍ [illegible] របស់ស្ថានីយទូរទស្សន៍សម្រាប់ចាក់ផ្សាយតាមស្ថានីយទូរទស្សន៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន។

**មាត្រា១២ ._**

ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមប្រជុំពិនិត្យនិងសម្រេចលើស្នាដៃភាពយន្តទាំងនោះតាមការអញ្ជើញរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**មាត្រា១៣ ._**

ការអនុញ្ញាតប្រកបអាជីវកម្មផលិតស្នាដៃភាពយន្ត អាជីវកម្មភាពយន្ត អាជីវកម្មរោងបញ្ចាំងភាពយន្ត សេវាកម្មផ្គត់ផ្គង់សម្ភារៈថតភាពយន្ត សេវាកម្មកាត់តដំឡើងរូបភាព ផ្គុំសំឡេងនិងថតចម្លងភាពយន្ត សេវាកម្មបកប្រែបញ្ចូលសំឡេងភាពយន្ត សេវាកម្មស្ទូឌីយោថតភាពយន្ត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈភាពយន្ត ដូចមានចែងក្នុងមាត្រា៦ ការផ្តល់ទិដ្ឋាការស្នាដៃភាពយន្តដូចមានចែងក្នុងមាត្រា១១ ត្រូវបង់កម្រៃសេវាសាធារណៈ ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## ការត្រួតពិនិត្យលើឧស្សាហកម្មភាពយន្ត

**មាត្រា១៤ ._**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ ការប្រកបអាជីវកម្មផលិតស្នាដៃភាពយន្ត ការធ្វើអាជីវកម្មភាពយន្ត ការធ្វើអាជីវកម្មរោងបញ្ចាំងភាពយន្ត ការចែកចាយភាពយន្ត ការធ្វើសេវាកម្មផ្គត់ផ្គង់សម្ភារៈថតភាពយន្ត ការធ្វើសេវាកម្មកាត់តដំឡើងរូបភាព ការផ្គុំសំឡេងនិងថតចម្លងភាពយន្ត ការធ្វើសេវាកម្មបកប្រែបញ្ចូលសំឡេងភាពយន្ត ការធ្វើសេវាកម្មស្ទូឌីយោថតភាពយន្ត សាលាបណ្តុះបណ្តាលវិជ្ជាជីវៈភាពយន្ត និងការផ្សព្វផ្សាយស្នាដៃភាពយន្ត។

**មាត្រា១៥ ._**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីមានសមត្ថកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម។

ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីមានសមត្ថកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**មាត្រា១៦ ._**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

- ការបង្គាប់ឱ្យកែតម្រូវសកម្មភាព
- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការផ្អាកលិខិតអនុញ្ញាតការផលិត ការធ្វើអាជីវកម្ម ការធ្វើសេវាកម្ម និងទិដ្ឋាការស្នាដៃភាពយន្តជាបណ្ដោះអាសន្ន
- ការដកហូតលិខិតអនុញ្ញាតការផលិត ការធ្វើអាជីវកម្ម ការធ្វើសេវាកម្ម និងទិដ្ឋាការស្នាដៃភាពយន្ត និង
- ការពិន័យអន្តរការណ៍។

**មាត្រា១៧ ._**

ការបង្គាប់ឲ្យកែតម្រូវសកម្មភាព ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាកលិខិតអនុញ្ញាតការផលិត ការធ្វើអាជីវកម្ម ការធ្វើសេវាកម្ម និងទិដ្ឋាការស្នាដៃភាពយន្តជាបណ្ដោះអាសន្ន ការដកហូតលិខិតអនុញ្ញាត ការផលិត ការធ្វើអាជីវកម្ម ការធ្វើសេវាកម្ម និងទិដ្ឋាការស្នាដៃភាពយន្តជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីជំនាញរបស់នាយកដ្ឋានសិល្បៈភាពយន្តនិងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យ ចំពោះអំពើល្មើស ដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឲ្យរលត់បណ្ដឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី។

**មាត្រា១៨ ._**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៣ ០០០ ០០០(បីលាន)រៀល ចំពោះជនណាដែលផលិតស្នាដៃភាពយន្ត អាជីវកម្មភាពយន្ត អាជីវកម្មរោងបញ្ចាំងភាពយន្ត សេវាកម្មផ្គត់ផ្គង់សម្ភារៈថតភាពយន្ត សេវាកម្មកាត់តតម្លើងរូបភាព ផ្គុំសំឡេងនិងថតចម្លងភាពយន្ត សេវាកម្មបកប្រែបញ្ចូលសំឡេងភាពយន្ត សេវាកម្មស្ទូឌីយោថតភាពយន្ត សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈភាពយន្តដោយគ្មានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ករណីដែលទទួលរងការពិន័យអន្តរការណ៍រួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ត្រូវផ្ដន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា១៩ ._**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៣ ០០០ ០០០(បីលាន)រៀល ចំពោះជនណាដែលចែកចាយ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយនូវរាល់ស្នាដៃភាពយន្ត និងផ្សព្វផ្សាយស្នាដៃភាពយន្ត ដោយគ្មានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២០ ._**

ជនណាដែលយកស្នាដៃភាពយន្តគ្មានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈទៅជួល លក់ ឬធ្វើសន្និធិក្នុងគោលបំណងជួលឬលក់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ២០ ០០០(ពីរម៉ឺន)រៀល សម្រាប់សម្ភារៈផ្ទុកស្នាដៃភាពយន្តមួយ។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២១ ._**

វត្ថុតាងនៃបទល្មើសដូចមានចែងក្នុងមាត្រា១៩និងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវចាប់យកដោយមន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យលើឧស្សាហកម្មភាពយន្ត។

ការសម្រេចចាត់ចែងវត្ថុតាងត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២២ ._**

មន្ត្រីរាជការទាំងឡាយដែលមានភារកិច្ចពិនិត្យខ្លឹមសារនិងរូបភាពស្នាដៃភាពយន្ត ត្រួតពិនិត្យ ឬបង្ក្រាបបទល្មើសភាពយន្ត មានការឃុបឃិត ឬប្រព្រឹត្តរំលោភភារកិច្ចរបស់ខ្លួនផ្ទុយពីបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលដោយមិនទាន់គិតអំពីទោសព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា២៣ ._**

ផលិតករភាពយន្ត អ្នកប្រកបអាជីវកម្ម សេវាកម្មស្នាដៃភាពយន្តដែលមិនទាន់បានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

# ជំពូកទី៨
# អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

អនុក្រឹត្យលេខ៦៣ អនក្រ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៣៤ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៦
## ស្តីពី
## ការគ្រប់គ្រងឧស្សាហកម្មភាពយន្ត

១. ស្នាដៃ សំដៅដល់ផលិតផលខាងវិស័យសិល្បៈវប្បធម៌ កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញាឬមនោសញ្ចេតនា។

២. ភាពយន្ត សំដៅដល់វត្ថុមានសំឡេងឬគ្មានសំឡេងដែលមានរូបភាពតជាសេរី ផ្ទុកនៅលើសម្ភារៈ ហ្វីល កាសែ្សត ឌីស អង្គចងចាំ និងរាល់សម្ភារៈផ្ទុកផ្សេងៗទៀត ដែលអាចមើលឃើញបានតាមរយៈការចាក់បញ្ចាំង។

**៣. ស្នាដៃភាពយន្តជាស្នាដៃដោយឡែកណាមួយ រួមមាន៖**

- ស្នាដៃភាពយន្តរឿងខ្នាតវែង ខ្នាតខ្លី
- ស្នាដៃភាពយន្តទូរទស្សន៍ខ្នាតវែង ខ្នាតខ្លី
- ស្នាដៃភាពយន្តរឿងភាគ
- ស្នាដៃភាពយន្តឯកសារខ្នាតវែង ខ្នាតខ្លី
- ស្នាដៃភាពយន្តគំនូរជីវចល តុក្កតា
- ស្នាដៃភាពយន្តពាណិជ្ជកម្ម
- ស្នាដៃភាពយន្តចម្រៀង ចម្រៀងកាយវិការ ខារ៉ាអូខេ។

៤. ឧស្សាហកម្មភាពយន្ត សំដៅដល់សកម្មភាពការងារដែលទាក់ទងទៅនឹងការបណ្តុះបណ្តាលជំនាញ ការផលិត ការធ្វើសេវាកម្ម ការធ្វើអាជីវកម្ម ការចែកចាយ និងការផ្សព្វផ្សាយស្នាដៃភាពយន្ត។

៥. លិខិតអនុញ្ញាត សំដៅដល់ការអនុញ្ញាតផ្តល់អាជ្ញាបណ្ណផលិតកម្មភាពយន្ត អាជ្ញាបណ្ណសេវាកម្ម អាជីវកម្មភាពយន្ត ការអនុញ្ញាតផលិតស្នាដៃភាពយន្ត ការអនុញ្ញាតផ្តល់ទិដ្ឋាការស្នាដៃភាពយន្ត។

៦. ការផលិតស្នាដៃភាពយន្ត សំដៅដល់សកម្មភាពការងារ រាប់ចាប់តាំងពីដំណាក់កាលត្រៀមមុនពេលថត ពេលដំណើរការថត និងការងារក្រោយពេលថតរហូតដល់បានជាផលិតផលសម្រេច។

៧. អត្ថបទនិពន្ធភាពយន្ត សំដៅដល់សាច់រឿង សង្ខេបរឿង អត្ថបទរឿងពិស្តារ ជាភាសាជាតិមានពាក្យសន្ទនា ទំនុកច្រៀង។

៨. ការចាក់បញ្ចាំងភាពយន្ត សំដៅដល់សកម្មភាពនៃការបញ្ចេញរូបភាពនិងសំឡេងនៃស្នាដៃភាពយន្តឲ្យលេចឡើងនៅលើអេក្រង់ឬផ្ទាំងសំពត់ស ដោយមធ្យោបាយបច្ចេកទេសផ្សេងទៀត។

៩. ការផ្សព្វផ្សាយស្នាដៃភាពយន្ត សំដៅដល់សកម្មភាពនៃការបញ្ចាំងភាពយន្ត និងឬការបញ្ជូនរូបភាព និងសំឡេងនៃស្នាដៃភាពយន្តឲ្យដល់គោលដៅ តាមរយៈរលកអាកាស ប្រព័ន្ធទូរទស្សន៍ ទូរទស្សន៍ខ្សែកាប អ៊ីនធឺណិត និងមធ្យោបាយផ្សេងទៀត។

១០. ការផ្សព្វផ្សាយជាសាធារណៈ សំដៅដល់ការផ្សព្វផ្សាយស្នាដៃភាពយន្តក្រៅរង្វង់គ្រួសារដែលអាចឲ្យសាធារណៈជនទទួលនូវរូបភាពនិងសំឡេងនៃស្នាដៃភាពយន្តនោះ។

១១. ការចែកចាយភាពយន្ត សំដៅដល់សកម្មភាពគ្រប់គ្រង ធ្វើចរាចរណ៍នាំចេញ នាំចូល និងចែកចាយស្នាដៃភាពយន្ត នៅលើទីផ្សារភាពយន្ត។

១២. អាជីវកម្មភាពយន្ត សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិតស្នាដៃ លក់ ទិញ ជួល នាំចេញ នាំចូល និងចែកចាយស្នាដៃភាពយន្ត។

១៣. សេវាកម្មភាពយន្ត សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ដែលមានគោលដៅទាញយកប្រាក់ចំណូលឬអត្ថប្រយោជន៍អ្វីមួយពីការផ្គត់ផ្គង់សេវាកម្មផ្សេងៗដល់ការផលិតស្នាដៃភាពយន្តមានដូចជា ផ្គត់ផ្គង់សម្ភារៈថតភាពយន្ត ស្ទូឌីយោថតភាពយន្ត ស្ទូឌីយោដំឡើងរូបភាព ផ្គុំសំឡេងនិងថតចម្លង ស្ទូឌីយោបញ្ចូលសំឡេង។ល។

១៤. សេវាកម្មផ្គត់ផ្គង់សម្ភារៈថតភាពយន្ត សំដៅដល់ការធ្វើសកម្មភាពផ្តល់សេវាកម្មជួលឧបករណ៍ សម្ភារៈដែលបម្រើដល់ការថតភាពយន្តក្នុងនោះរួមមាន៖

- សម្ភារៈភ្លើងបំភ្លឺថតភាពយន្ត (Lighting Equipment)
- កាមេរ៉ាថតភាពយន្តនិងឧបករណ៍ជំនួយកាមេរ៉ា (Camera and Accessories)
- ឧបករណ៍ជំនួយថតភាពយន្ត (Grip Equipment)

លើកលែងតែសម្ភារៈបរិក្ខារបម្រើដល់ការផលិតកម្មវិធីទូរទស្សន៍ ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងព័ត៌មាន។

១៥. រោងភាពយន្ត សំដៅដល់បន្ទប់មួយឬសំណុំបន្ទប់ស្ថិតនៅក្នុងអគារតែមួយដែលរៀបចំឡើងជាពិសេសមានលក្ខណៈអចិន្ត្រៃយ៍សម្រាប់ធ្វើការបញ្ចាំងភាពយន្តដោយប្រើនូវគ្រប់វិធីសាស្ត្រដាក់ផ្ទាំងសំពត់ឬឧបករណ៍បញ្ចាំងរូបភាព និងប្រភេទឧបករណ៍ផ្ទុកស្នាដៃភាពយន្ត។